**WWF-Cambodia**

21, Street 322,
Boeung Keng Kang I,
Phnom Penh, Cambodia
P.O. Box: 2467

Tel: +855 23 218 034
Fax: +855 23 211 909

www.wwf.org.kh
www.panda.org/greatermekong
wwfcambodia@wwf.org.kh

*for a living planet*®

**សេចក្តីប្រកាសសារព័ត៌មាន** **សម្រាប់ចេញផ្សាយបន្ទាន់**

# អង្គការ WWF និងអគ្គនាយកដ្ឋានកៅស៊ូ ប្រកាសជាផ្លូវការ គម្រោងភាពជាដៃគូពហុភាគីសម្រាប់អភិវឌ្ឍន៍វិស័យកៅស៊ូប្រកបដោយនិរន្តរភាព

អង្គការ WWF-កម្ពុជា និងអគ្គនាយកដ្ឋានកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះអនុស្សារណៈយោគយល់កាលពីម្សិលមិញ ដើម្បីចាប់ផ្តើមកិច្ចសហប្រតិបត្តិការជាលើកដំបូងក្នុងការកសាងដៃគូពហុភាគី សម្រាប់ការលើកម្ពស់ខ្សែចង្វាក់ផ្គត់ផ្គង់កៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព និងតម្លាភាពក្នុងប្រទេសកម្ពុជា។

ក្រោមជំនួយថវិការបស់ក្រសួងកិច្ចសហប្រត្តិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (BMZ) របស់ប្រទេសអាល្លឺម៉ង់ តាមរយៈអង្គការ Welthungerhilfe កិច្ចសហប្រតិបត្តិការភាពជាដៃគូពហុភាគីនេះ កំពុងត្រូវបានអនុវត្តក្នុងប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលរួមមានទាំងប្រទេសថៃ និងភូមា ផងដែរ។

ក្នុងប្រទេសកម្ពុជា កិច្ចសហប្រតិបិត្តការរយៈពេលបីឆ្នាំនេះ បានជម្រុញការចូលរួមនិងសហការណ៍ពីភាគីពាក់ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល វិស័យឯកជន អង្គការសង្គមស៊ីវិល និងកសិករកៅស៊ូគ្រួសារ ក្នុងខេត្តមណ្ឌលគិរី ដើម្បីជម្រុញផលិតកម្មកៅស៊ូធម្មជាតិប្រកបដោយចីរភាព ព្រមទាំងរួមចំណែកដល់ការលើកកម្ពស់ជីវភាពកសិករកៅស៊ូគ្រួសារ ជនជាតិដើមភាគតិច និងកម្មករកៅស៊ូផងដែរ។

"ការលើកកម្ពស់ផលិតកម្មកៅស៊ូគ្រួសារប្រកបដោយនិរន្តរភាពនិងទំនួលខុសត្រូវខ្ពស់តាមរយៈការអនុវត្តការគ្រប់គ្រងបច្ចេកទេសបានយ៉ាងល្អត្រឹមត្រូវនៅក្នុងប្រទេសកម្ពុជា មិនត្រឹមតែជួយបង្កើតការងារនិងចំណូលដល់សហគមន៍មូលដ្ឋានប៉ុណ្ណោះទេ វាក៏ជួយកាត់បន្ថយសម្ពាធលើធនធានធម្មជាតិផងដែរ តាមរយៈការប្រើប្រាស់ដីដាំកៅស៊ូដែលមានស្រាប់ឲ្យអស់សុពលភាព និងទប់ស្កាត់ការទន្ទ្រានដីព្រៃខុសច្បាប់។ ពិធីចុះអនុស្សារណៈយោគយល់គ្នានេះបានបើកទំព័រថ្មីមួយទៀតសម្រាប់អង្គការ WWF-កម្ពុជា លើកិច្ចខិតខំប្រឹងប្រែងធ្វើការងារក្នុងភាពជាដៃគូជាមួយស្ថាប័នជំនាញនិងមានទំនួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា" ប្រសាសន៍ **លោក សេង ទៀក** នាយកអង្គការ WWF-កម្ពុជា។

អនុស្សារណៈយោគយល់នេះ គាំទ្រឆន្ទៈរួមគ្នា ក្នុងការបង្កើតឱ្យមានយន្តការភាពជាដៃគូពហុភាគី ដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់អាចចែករំលែកចំណេះដឹងនិងព័ត៌មានស្តីអំពីផលិតកម្មកៅស៊ូប្រកបដោយនិរន្តរភាព ព្រមទាំងអាចចូលរួមក្នុងគោលនយោបាយជម្រុញខ្សែចង្វាក់ផ្គត់ផ្គង់កៅស៊ូធម្មជាតិប្រកបដោយចីរភាពផងដែរ។ អនុស្សារណៈយោគយល់នេះ ក៏ផ្តល់ឱកាសក្នុងការកសាងសមត្ថភាពក្នុងការអនុវត្តផលិតកម្មកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព ខណៈលើកកម្ពស់ការចូលរួមចំណែករបស់កសិករកៅស៊ូគ្រួសារក្នុងកិច្ចការពារធនធានធម្មជាតិក្នុងសហគមន៍របស់ពួកគេ។

**ឯកឧត្តម ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ មានប្រសាសន៍ថា "ការកសាងសមត្ថភាព និងបណ្តុះបណ្តាលបច្ចេកទេសដល់កសិករដាំកៅស៊ូ និងមន្ត្រីជំនាញផ្នែកកៅស៊ូ បូករួមទាំងការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យកៅស៊ូនេះ នឹងធ្វើឱ្យវិស័យកៅស៊ូក្នុងប្រទេសកម្ពុជាកាន់តែរីកចម្រើនទៅមុខប្រកបដោយចីរភាព។"

ដើម្បីជាជំនួយស្មារតីក្នុងការអនុវត្តផលិតកម្មកៅស៊ូប្រកបដោយនិរន្តរភាព អគ្គនាយកដ្ឋានកៅស៊ូ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការ WWF និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) បានសហការបោះពុម្ពផ្សាយសៀវភៅណែនាំបច្ចេកទេសសម្រាប់ការអនុវត្តកសិកម្មល្អ (GAP) លើការយកផលទឹកជ័រកៅស៊ូ និងបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល បូករួមទាំងការបង្ហាញការអនុវត្តដើម្បីទទួលបានបទពិសោធន៍បច្ចេកទេសដោយផ្ទាល់នៅតាមចម្ការកៅស៊ូគ្រួសារមួយចំនួនផងដែរ ទៅដល់កសិករកៅស៊ូគ្រួសារចំនួន និងមន្ត្រីជំនាញផ្នែកកៅស៊ូរបស់រាជរដ្ឋាភិបាល សរុបចំនួន ៦០ នាក់ មកពីខេត្តចំនួន ២០ នៃប្រទេសកម្ពុជា។

បច្ចុប្បន្ននេះ កសិករកៅស៊ូគ្រួសារ ចំនួន ១០០ នាក់ ដែលរស់នៅជុំវិញសហគមន៍តំបន់ការពារចំនួនប្រាំ នៅជិតដែនជម្រកសត្វព្រៃស្រែពកក្រោមការគាំទ្រដោយអង្គការ WWF បានចូលរួមក្នុងគម្រោងនេះរួចមកហើយ ហើយគម្រោងនឹងបន្តជម្រុញការចូលរួមរបស់កសិករកៅស៊ូគ្រួសាររហូតដល់ ៣០០ គ្រួសារត្រឹមឆ្នាំ២០២២។

**************************

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
**លោក ទេព អស្នារិទ្ធ** ប្រធានកិច្ចការសាធារណៈ និងគ្រប់គ្រងព័ត៌មាននៃអង្គការ WWF-កម្ពុជា
អ៊ីម៉ែល៖ asnarith.tep@wwf.org.kh ទូរស័ព្ទ៖ ០១២ ៩៥៧ ៥១៩

ព័ត៌មានសម្រាប់អ្នកនិពន្ធ៖
តំណរសម្រាប់ទាញយករូបភាព៖ https://bit.ly/2K7aRcx

អំពី WWF
អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ (WWF) ជាអង្គការអភិរក្សធម្មជាតិឯករាជ្យមួយ ដែលមានអ្នកគាំទ្រជាង៣០លាននាក់ និងមានបណ្តាញបេសកកម្មនៅក្នុង១០០ប្រទេសលើពិភពលោក។ បេសកកម្មរបស់យើងគឺបញ្ឈប់ការ រេចរឹលនៃបរិស្ថានធម្មជាតិរបស់ភពផែនដី និងដើម្បីកសាងអនាគតមួយដែលមនុស្សរស់នៅដោយសុខដុមជាមួយនឹងធម្មជាតិ តាមរយៈការអភិរក្សជីវៈចម្រុះរបស់ពិភពលោក ធានាការប្រើប្រាស់ដោយចីរភាពនូវធនធានកកើតឡើងវិញ និងលើកកម្ពស់ការកាត់បន្ថយការបំពុលនិងការប្រើប្រាស់ខ្ជះខ្ជាយ។

សូមចូលចូលទៅកាន់ទំព័រ Facebook និង Twitter របស់យើងដើម្បីទទួលបាននូវដំណឹងថ្មីៗ និងសូមចូលទៅកាន់គេហទំព័ររបស់យើងគឺ www.wwf.org.kh ដើម្បីទទួលបានព័ត៌មានផ្សេងៗទៀត។